# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងធម្មការ និង សាសនា**

លេខ ៧៥១ ក.ធ.សក

## សេចក្តីសំរេច

ស្តីពីការអនុញ្ញាតឲ្យ បំឲ្យរុះរើ ព្រះវិហារចាស់ កសាងជាថ្មីដែលស្ថិតនៅ "វត្តលក្ខរាជា"
នៃគណៈមហានិកាយ ភូមិលក្ខរាជា ឃុំកំពង់ចក ស្រុកវ៉ដូល ខេត្តស្វាយរៀង

### រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.
- បានឃើញព្រះរាជក្រមលេខ នស.រកម០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា.
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា.
- យោងតាមចំណារឯកភាពរបស់អភិបាល ខេត្ត ស្វាយរៀង លេខ ២០៧ ធប.សកិ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០០២.
- យោងតាមចំណាររបស់ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង លេខ ៥៤ មធក.ស្វរ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០២.
- យោងតាមចំណាររបស់អភិបាលស្រុកវ៉ដូល លេខ ១១២ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០២.
- តាមសំណើសុំកសាងវត្ត របស់ចៅអធិការ និងអាចារ្យ គណៈកម្មការ វត្ត លក្ខរាជា ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០២.

### សំរេច

**ប្រការមួយៈ** អនុញ្ញាតឱ្យរុះរើ ព្រះវិហារចាស់ កសាងជាថ្មី "វត្តលក្ខរាជា" នៃគណៈមហានិកាយ ដែលស្ថិតនៅក្នុង ភូមិ លក្ខរាជា ឃុំកំពង់ចក ស្រុកវ៉ដូល ខេត្តស្វាយរៀង ដោយរក្សានូវក្បាច់រចនា ជាវប្បធម៌របស់ជាតិ ។

**ប្រការពីរ :** ព្រះវិហារថ្មីនេះ ត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបានត្រឹមត្រូវ តាមពុទ្ធបញ្ញត្តិ និងពុទ្ធានុញ្ញាត និង ប្រពៃណីពុទ្ធសាសនាព្រមទាំងច្បាប់របស់រដ្ឋ ឱ្យបានល្អប្រសើរ និងរីកចំរើន ។

**ប្រការបី :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអាចារ្យ- គណៈកម្មការវត្ត ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០២

**រដ្ឋមន្ត្រី**

ជា-សាវឿន

**ចម្លងជូន :**

- សម្តេចព្រះសង្ឃរាជគណៈមហានិកាយ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
"ដើម្បីថ្វាយ-ជូនជ្រាប"
- រាជកិច្ច "ដើម្បីចុះផ្សាយ"
- សាលាខេត្តស្វាយរៀង
- អភិបាលស្រុកវ៉ដូល
- ដូចប្រការបី
"ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ